ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តាមនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្ត កំពង់ធំ

ក្រុមប្រឹក្សាជំនុំជម្រះទី ១

-សំណុំរឿងព្រហ្មទណ្ឌលេខ : ៦៣៩
ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២

-សំណុំរឿងជំនុំជម្រះលេខ : ៥៥៤
ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០២២

-សាលក្រមព្រហ្មទណ្ឌលេខ : ០៩ "ក"
ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២៣

-បានឃើញ ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ : នស / រកម / ០៧១៤ / ០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។

-ថ្ងៃបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៣ ។

-ថ្ងៃប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃពុធ ១៤រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០២៣ ។

**សមាសភាពចូលរួមសវនាការ មានដូចខាងក្រោម :**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ឯកឧត្តម | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាព្រះរាជអាជ្ញារង |
| កញ្ញា | [redacted] | ជាក្រឡាបញ្ជីសវនាការ |
| លោក | [redacted] | ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ |



Scanned with CamScanner

**សាលាដំបូងខេត្ត កំពង់ធំ បានបើកសវនាការជំនុំជម្រះលើរឿងព្រហ្មទណ្ឌលេខ : ៦៣៩ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២ ដែលជនជាប់ចោទមានសាវតាជាតិ ដូចខាងក្រោម :**

**-ឈ្មោះ [redacted] ឆេន ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ ។**

**-ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកំពង់ធំ ។**

**-ទីលំនៅសព្វថ្ងៃនៅភូមិ[redacted] ខេត្តកំពង់ធំ ។**

**-ប្រពន្ធឈ្មោះ [redacted] ធុន មានកូន ០៣ នាក់ ។**

**-ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted]គុន (រស់)។**

**-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ ឃាត់ខ្លួនថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ ។**

**ជាប់ចោទ ពីបទ : អំពើលួច មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិដាំក្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ [redacted] **ឃាង** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិដាំក្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ [redacted] ស្រីម៉ៅ មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted]ខុន (រស់) ម្តាយឈ្មោះ [redacted]រ៉ា (រស់) ។

## បានឃើញ

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ : ៥៥៤ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្ត កំពង់ធំ ។

-បានឃើញ ដីកាដំណោះស្រាយលេខ : ៥៤៣១ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្ត កំពង់ធំ ។

-បានឃើញ ដីការចាត់ក្រុមប្រឹក្សាជំនុំជម្រះលេខ : ៦៦៦ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្ត កំពង់ធំ ។

-បានឃើញ ភស្តុតាង និង ឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោង ១១.៥០ នាទីយប់ មានបទល្មើស អំពើ លួច មានស្ថានទម្ងន់ទោស កើតឡើងនៅចំណុចភូមិដាំក្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ឆេន ភេទ ប្រុស អាយុ ៥២ ឆ្នាំ បានធ្វើសកម្មភាព[illegible] [illegible]ណី



Scanned with CamScanner

វីស និង ដង្កាប់ ទៅចាក់សោរកម៉ូតូ ម៉ាកហុងដា សេ១២៥ ផលិតឆ្នាំ ២០១២ ពណ៌ខ្មៅ ចំនួន ០១ គ្រឿង ជារបស់ជនរងគ្រោះឈ្មោះ [redacted] យាង ភេទប្រុស រួចហើយបានជិះទៅដេកនៅផ្ទះប្រពន្ធចុងរបស់ខ្លួន នៅភូមិថ្មី ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយដោះដូរតែមឡើងឆ្នាំផលិត ២០១៥ រហូតដល់ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២២ ជនជាប់ចោទបានជិះម៉ូតូទៅផ្សារកំពង់ថ្ម ក៏ត្រូវសមត្ថកិច្ចឃាត់តែម្តង ។

ចំពោះវត្ថុដែលចាប់យកពីខ្លួនជនជាប់ចោទមាន : ទូរស័ព្ទម៉ាក ណូគា ចំនួន ០១ គ្រឿង , សោរ ចំនួន ០១ , ទួល ណឺវីស ចំនួន ០១ , ដង្កាប់ ចំនួន ០១ និង **ម៉ូតូម៉ាក ហុងដា** សេ១២៥ ពណ៌ខ្មៅ ផ្លាក លេខ **ត្បូងឃ្មុំ** ១C ៥៥២៦ ចំនួន ០១ គ្រឿង ។

ចំណែកម៉ូតូ ហុងដា សេ១២៥ ពណ៌ខ្មៅ ផ្លាក លេខ ត្បូងឃ្មុំ ១C ៥៥២៦ ចំនួន ០១ គ្រឿង ត្រូវបានអធិការដ្ឋាននគរបាលស្រុកបារាយណ៍ ប្រគល់ឱ្យទៅម្ចាស់ឈ្មោះ ឃួន យាង កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២២ វិញហើយ ។

<u>**ចំលើយពិតាក្យរដេញដោលនាពេលសវនាការមាន**</u> :

**១–ជនជាប់ចោទឈ្មោះ [redacted] សេន ភេទប្រុស អាយុ ៥២ ឆ្នាំ បានឆ្លើយបញ្ជាក់ថា :** ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ខ្លួនសុំឆ្លើយបញ្ជាក់បន្ថែមនាពេលសវនាការនេះថា នៅថ្ងៃកើតហេតុថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០២២ ខ្លួនបានចេញពីផ្ទះតាំងពីម៉ោង ២–៣ទៀបភ្លឺ មកស៊ីឈ្នួលបាញ់ថ្នាំដំឡូងឱ្យឈ្មោះ បេន នៅភូមិក្រវ៉ា ឃុំក្រវ៉ា ពេលខ្លួនបាញ់ថ្នាំរួច ខ្លួនបានដើរមកវិញមកដល់ភូមិត្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានឃើញផ្ទះមួយខ្លួនមិនស្គាល់ ឃើញគេកំពុងផឹកស៊ីនៅក្រោមផ្ទះនោះ ហើយខ្លួនបានឃើញម៉ូតូចំនួន ០២គ្រឿង ខ្លួនក៏បានអង្គុយចាំមើលរហូតដល់ម៉ោង១១យប់ ទើបពួកគេនាំគ្នាឈប់ផឹក ហើយបានជិះម៉ូតូ០១គ្រឿងទៅបាត់ នៅសល់ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ទុកចោលក្រោមផ្ទះ ហើយម្ចាស់ឡើងទៅដេកលើផ្ទះអស់ មួយសន្ទុះពេលស្ងាត់ខ្លួនក៏បានចូលលួចយកម៉ូតូនោះ ប៉ុន្តែម៉ូតូនោះម្ចាស់គេចាក់សោរកជាប់ ខ្លួនក៏បានយកដង្កាប់ដែករបស់ខ្លួន ដែលខ្លួនបានឆាបកន្ទុយដង្កាប់នោះឱ្យមានរាងស្តើងតូចទំហំប៉ុនកូនសោរ យកទៅចាក់រុកចូលរន្ធសោរម៉ូតូហើយកាច់បំបែកគ្រាប់សោរម៉ូតូនោះ រួចហើយខ្លួនក៏បានបណ្តើរម៉ូតូចេញមកក្រៅបញ្ជោះជិះមកផ្ទះរបស់ខ្លួននៅភូមិថ្មី ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំតែម្តង ។

នៅថ្ងៃទី ០៦ ខែ សីហា វេលាម៉ោងប្រហែល **៧យប់** ខ្លួនបានធ្វើការ ដោះផ្លាកម៉ូតូចេញ ហើយនៅព្រឹកឡើងខ្លួនជិះម៉ូតូនោះទៅទិញតែម ហើយបានបកតែមឆ្នាំ ២០១២ ចោល ដោយបិតតែមឆ្នាំ ២០១៥ វិញ ។

នៅថ្ងៃទី០៩ ខែ សីហា វេលាម៉ោងប្រហែល **៣រសៀល** ខ្លួនបានជិះម៉ូតូមកផ្សារកំពង់ថ្ម ដើម្បីយកម៉ូតូនោះមកធ្វើសោរវិញ ពេលជិះមកដល់ពាក់កណ្តាលផ្លូវក៏សមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

**២–អំណានកំណត់ហេតុបណ្ដឹងរបស់ឈ្មោះ [redacted] ឃាង ភេទប្រុស បានឆ្លើយបញ្ជាក់នៅចំពោះមន្ត្រីនគរបាលយុត្តិធម៌ កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២ ថា :** ខ្លួនមានម៉ូតូ ០១គ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ផលិតឆ្នាំ ២០១២ ពាក់ផ្លាកលេខ ត្បូងឃ្មុំ 1G ៥៥២៦ ដែលខ្លួនជិះទៅធ្វើការ នៅភូមិស្រឡៅ ហើយរាល់យប់ក្រោយពីធ្វើការខ្លួនតែងតែចាក់សោរកទុកក្រោមផ្ទះ ។ នៅម៉ោងប្រហែល ៨.៣០នាទីយប់ មិត្តភ័ក្ត្រដែលធ្វើការជាមួយខ្លួនចំនួន **០៣នាក់** បានទិញស្រាបៀរចំនួន **០១កេស** ដើម្បីយកផឹកស៊ីនៅផ្ទះរបស់ខ្លួន និងមិត្តភ័ក្ត្ររបស់ខ្លួនក្នុងភូមិចំនួន **០៣នាក់**ទៀត បានមកផឹកស៊ីជាមួយ ។

លុះដល់ម៉ោងប្រហែល ១១យប់ ពួកខ្លួនបាននាំគ្នាឈប់ផឹក ក៏បែកគ្នាទៅផ្ទះរៀងៗខ្លួន ហើយខ្លួនបានចាក់សោរម៉ូតូរួចហើយបានឡើងទៅដេកនៅលើផ្ទះ ដល់ម៉ោង ៦ព្រឹក កូនរបស់ខ្លួនបានចុះពីលើផ្ទះមុនក៏ឃើញបាត់ម៉ូតូវាបានស្រែកប្រាប់ ហើយខ្លួនចុះមកមិនឃើញក៏ទៅប្ដឹងសមត្ថកិច្ចតែម្ដង ។

**៣–អំណានរបាយការណ៍របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ** ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល លេខ : **៨២** ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២២ **ការសន្និដ្ឋាន :** តាមការស្រាវជ្រាវ និង ការប្រមែប្រមូលបណ្ដាឯកសារភស្ដុតាងដែលស៊ីសង្វាក់ យើងសន្និដ្ឋានបានថា ជនសង្ស័យឈ្មោះ ឈិត ឆេន ភេទប្រុស អាយុ ៥២ ឆ្នាំ ទីលំនៅភូមិថ្មី ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ **ខេត្តកំពង់ធំ** ធ្លាប់ជាប់ពន្ធនាគារចំនួន ០២ដង ពាក់ព័ន្ធនឹងបទល្មើសលួច (ករណីមិនរាងចាល) ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តបទល្មើស លួចកាច់សោរកម៉ូតូចំនួន ០១ **គ្រឿង ដែលជាកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ ឃួន ឃាង** ភេទប្រុស អាយុ ៣៨ឆ្នាំ រស់នៅភូមិឃុំកើតហេតុ **កាលពីថ្ងៃទី** ០៤ ខែ សីហា ឆ្នាំ ២០២២ **ម៉ោងប្រហែល** ២៣.៥០នាទី នៅចំណុចភូមិជាំត្រាច ឃុំឈូក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ពិតប្រាកដមែន ។

**សេចក្ដីកត់សម្គាល់ខ្លីៗ និង សំណូមពរចុងក្រោយរបស់ជនជាប់ចោទ**

–ជនជាប់ចោទឈ្មោះ [redacted] ឆេន បានឆ្លើយបញ្ជាក់ថា ខ្លួនមិនមានអ្វីឆ្លើយបញ្ជាក់បន្ថែមទៀត ខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

**តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា :**

ឆ្លងតាមការសួរដេញដោលនាពេលសវនាការរួចមកតំណាងអយ្យការយល់ឃើញថា : ជនជាប់ចោទបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួន គឺជនជាប់ចោទបានសារភាពថា ខ្លួនពិតជាបានលួចយកម៉ូតូរបស់គេម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ ដែលបានទុកនៅក្រោមផ្ទះ ដោយខ្លួនបានយកកន្ទុយដង្កាប់ទៅចាក់ចូលក្នុងរន្ធសោរម៉ូតូកាច់បំបែកគ្រាប់សោរម៉ូតូ ហើយទៅផ្ទះរបស់ខ្លួន ពិតមែន ។

ចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីនាក់ឆ្លើយមកនេះ មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ និង ស៊ីសង្វាក់ភស្ដុតាងដែលមន្ត្រីនគរបាលយុត្តិធម៌ចាប់បានជាក់ស្ដែងពីខ្លួនជនជាប់ចោទ ។

មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឆេន ភេទប្រុស ពីបទ លួច មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិជាំក្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ។

ដូច្នេះ តំណាងអយ្យការប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា :**

ឆ្លងតាមការសួរដេញដោលនាពេលសវនាការរួចមកឃើញថា កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់តាំងពីដើមរហូតមកដល់ពេលសវនាការនេះ ដោយមិនកែប្រែចម្លើយរបស់ខ្លួនម្តងណាឡើយ នេះបង្ហាញឱ្យឃើញថាកូនរបស់ខ្លួនមានស្មារតីភ្ញាក់រលឹកដឹងកំហុសរបស់ខ្លួនដែលប្រព្រឹត្តឡើងមក ។

ដូច្នេះ ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាជួយបន្ធូបន្ថយទោសដល់កូនក្តីរបស់ខ្លួនផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារពាក់ពន្ធ័ក្នុងសំណុំរឿង

ក្រោយពីបានពិភាក្សាជាមួយក្រុមប្រឹក្សាជំនុំជម្រះ និង បានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាដំបូងខេត្ត កំពង់ធំ</u>**

**<u>យល់ឃើញថា</u>**

១-កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ វេលាម៉ោង ១១.៥០ នាទីយប់ ពិតជាមានបទល្មើស អំពើលួច មានស្ថានទម្ងន់ទោស កើតឡើងនៅចំណុចភូមិជាំក្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រព្រឹត្ត ឡើងដោយជនជាប់ចោទឈ្មោះ [redacted] ឆេន ភេទ ប្រុស អាយុ ៥២ ឆ្នាំ បានធ្វើសកម្មភាពយកសោរទួលណឺ វីស និង ដង្កាប់ ទៅចាក់សោកម៉ូតូ ម៉ាកហុងដា សេ១២៥ ផលិតឆ្នាំ ២០១២ ពណ៌ខ្មៅ ចំនួន ០១ គ្រឿង ជារបស់ជនរងគ្រោះឈ្មោះ [redacted] យាង ភេទប្រុស ពិតប្រាកដមែន ។

២-នាពេលសវនាការជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានលួចយកម៉ូតូរបស់គេដែលទុកនៅក្រោមផ្ទះ ដោយខ្លួនបានយកកន្ទុយដង្កាប់ដែលខ្លួនសំលៀងឱ្យតូចប៉ុនកូនសោរម៉ូតូទៅរុកចូលរន្ធសោរម៉ូតូ រួចហើយកាច់បំបែកគ្រាប់សោរ និង បានជិះម៉ូតូនោះទៅពិតប្រាកដមែន ។

អំពើរបស់ជនជាប់ចោទប្រព្រឹត្តឡើងមកនេះ គឺពិតជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយប្រើសកម្មភាពហិង្សាក្នុងពេលប្រព្រឹត្តពិតមែន ដូច្នេះ អំពើរបស់ជនជាប់ចោទនេះ គឺពិតជា អំពើលួច មានស្ថានទម្ងន់ទោស ដែលល្មើសនឹងមាត្រា ៣៥៣ និង មាត្រា ៣៥៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឃាង ភេទប្រុស បានទទួលសម្ភារៈរបស់ខ្លួនវិញហើយ ដោយមិនទាមទារសំណងអ្វីទៀតទេ ដូច្នេះតុលាការមិនលើកមកពិចារណាឡើយ ។

៤-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានតម្កល់បទចោទដែលមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និង ប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ការប្ដឹងសុំនេះ តុលាការនឹងទទួលមកពិចារណាតាមការស្នើសុំ ។

៥-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានស្នើសុំឱ្យតុលាការបន្ធូបន្ថយទោសដល់កូនក្ដីរបស់ខ្លួនផងការស្នើសុំនេះ តុលាការនឹងទទួលមកពិចារណាតាមច្បាប់ ។

៦-វត្ថុដែលចាប់យកមាន : ទូរស័ព្ទម៉ាក ណូគា ចំនួន ០១ គ្រឿង , សោរ ចំនួន ០១ , ទួល ណឺវីស ចំនួន ០១ និង ដង្កាប់ ចំនួន ០១ គប្បីតុលាការសម្រេចរឹបអូស ដោយយោងតាមមាត្រា ៦២ និង មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឆេន ភេទប្រុស អាយុ ៥២ ឆ្នាំ ដែលមានសាវតាជាតិខាងលើ ពីបទ : អំពើលួច មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិជាំត្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សាលាដំបូងខេត្ត កំពង់ធំ

## វិនិច្ឆ័យសេចក្ដី

**១-**ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ឆេន ភេទប្រុស អាយុ៥២ឆ្នាំ** ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ ឆ្នាំ (បួនឆ្នាំ) ដោយអនុវត្តទោសគិតពីថ្ងៃឃាត់ខ្លួនថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០២២ ។

**ពីបទ : អំពើលួច មានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិជាំត្រាច ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និង មាត្រា ៣៥៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២-វត្ថុដែលចាប់យកត្រូវរឹបអូសមាន : ទូរស័ព្ទម៉ាក ណូគា ចំនួន ០១ គ្រឿង , សោរ ចំនួន ០១ , ទូលណីវីស ចំនួន ០១ និង ដង្កាប់ ចំនួន ០១ ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

ក្រុមប្រឹក្សាជំនុំជម្រះមាន :

- លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- កញ្ញា [redacted] ជាក្រឡាបញ្ជី

---

បានថតចម្លងចេញត្រឹមត្រូវតាមសាលក្រមដើម

ថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅកំពង់ធំ . ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner